សំណើ

# 32 ដំឡើងប្រាក់ឈ្នួលអប្បបរមា។ លក្ខន្តិកៈផ្តួចផ្តើម។

## ចំណងជើងផ្លូវការ និងសេចក្តីសង្ខេប

រៀបចំដោយអគ្គព្រះរាជអាជ្ញា

**អត្ថបទស្តីពីវិធានការនេះអាចរកបាននៅទំព័រទី 97 និងនៅវ៉ិបសាយថ៍រដ្ឋលេខាធិការតាមរយ *voterguide.sos.ca.gov*។**

- ប្រាក់ឈ្នួលអប្បបរមារបស់ California បច្ចុប្បន្នគឺ $16 ក្នុងមួយម៉ោង។ វិធានការនេះបង្កើនកម្រិតអប្បបរមាដូចខាងក្រោម៖
  - និយោជកដែលមាននិយោជិតចាប់ផ្តើមពីចំនួន 26 នាក់ឡើងនឹងបង់ប្រាក់ឈ្នួល $17 ក្នុងមួយម៉ោងសម្រាប់រយៈពេលដែលនៅសេសសល់នៃឆ្នាំ 2024 និង $18 ក្នុងមួយម៉ោងនៅថ្ងៃទី 1, ខែមករា ឆ្នាំ 2025។
  - និយោជកដែលមាននិយោជិតស្មើ ឬតិចជាង 25 នាក់ នឹងផ្តល់ប្រាក់ឈ្នួល $17 ក្នុងមួយម៉ោងដោយចាប់ផ្តើមពីថ្ងៃទី 1 ខែមករា ឆ្នាំ 2025 និង $18 ក្នុងមួយម៉ោង ចាប់ផ្តើមពីថ្ងៃទី 1 ខែមករា ឆ្នាំ 2026។
- បន្ទាប់មក តាមច្បាប់ដែលមានចែង ប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំកែតម្រូវសម្រាប់អតិផរណា។
- បន្ថែមពីលើប្រាក់ឈ្នួលអប្បបរមាដែលអាចអនុវត្តបានជាទូទៅដែលបានពិពណ៌នាខាងលើ ច្បាប់បច្ចុប្បន្នបង្កើតប្រាក់ឈ្នួលអប្បបរមាខ្ពស់ជាងនេះនៅក្នុងឧស្សាហកម្មជាក់លាក់។ វិធានការនេះមិនធ្វើវិសោធនកម្មច្បាប់ទាំងនោះទេ។

### សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគនីតិបញ្ញត្តិ អំពីផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖

- ការចំណាយថ្នាក់រដ្ឋ និងមូលដ្ឋានអាចកើនឡើង ឬថយចុះ។ ការផ្លាស់ប្តូរនេះទំនងជានឹងមិនលើសពីកម្រិតខ្ពស់រាប់រយលានដុល្លារក្នុងមួយឆ្នាំៗនោះទេ។
- ចំណូលពន្ធរដ្ឋ និងមូលដ្ឋានទំនងជានឹងថយចុះ។ ការខាតបង់ប្រាក់ចំណូលនេះទំនងជានឹងមិនលើសពីពីរបីរយលានដុល្លារក្នុងមួយឆ្នាំនោះទេ។

32

## ការវិភាគដោយអ្នកវិភាគច្បាប់

# ផ្ទៃខាងក្រោយ

***ច្បាប់រដ្ឋ និងតំបន់ កំណត់ប្រាក់ឈ្នួលអប្បបរមា។*** និយោជកត្រូវបើកប្រាក់ឈ្នួលយ៉ាងហោចណាស់អប្បបរមាដល់កម្មករនិយោជិត។ ប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ California បច្ចុប្បន្នគឺ $16 ដុល្លារក្នុងមួយម៉ោង។ រដ្ឋាភិបាលក្នុងតំបន់ខ្លះមានប្រាក់ឈ្នួលអប្បបរមាខ្ពស់ជាងនេះ។ ច្បាប់ប្រាក់ឈ្នួលអប្បបរមាមិនអនុវត្តចំពោះអ្នកម៉ៅការឯករាជ្យ និងអ្នកធ្វើការដោយខ្លួនឯងផ្សេងទៀតទេ។

***ការកែតម្រូវអតិផរណានៅក្រោមច្បាប់បច្ចុប្បន្ន។*** តម្លៃមានទំនោរកើនឡើងតាមពេលវេលា។ ការកើនឡើងតម្លៃទាំងនេះត្រូវបានគេហៅថា “អតិផរណា”។ រដ្ឋកែសម្រួលប្រាក់ឈ្នួលអប្បបរមារបស់ខ្លួនជារៀងរាល់ឆ្នាំដោយផ្អែកលើអតិផរណា។ ការកែតម្រូវនីមួយៗត្រូវគ្នានឹងអតិផរណារបស់សហរដ្ឋអាមេរិក លើកលែងតែ*ករណីពីរ*៖

- ប្រសិនបើអតិផរណាអវិជ្ជមាន ការកែតម្រូវគឺសូន្យ។
- ប្រសិនបើអតិផរណាលើសពី 3.5 ភាគរយ ការកែតម្រូវគឺ 3.5 ភាគរយ។

***រដ្ឋកំណត់ប្រាក់ឈ្នួលអប្បបរមាខ្ពស់សម្រាប់និយោជកមួយចំនួន។*** ច្បាប់របស់រដ្ឋកំណត់ប្រាក់ឈ្នួលអប្បបរមាខ្ពស់ជាងនេះសម្រាប់និយោជកនៅក្នុងឧស្សាហកម្មមួយចំនួន។ ឧទាហរណ៍ភោជនីយដ្ឋានហ្វាសហ្វូតភាគច្រើនត្រូវផ្តល់ប្រាក់ឈ្នួលឱ្យបុគ្គលិករបស់ពួកគេយ៉ាងហោចណាស់ $20 ដុល្លារក្នុងមួយម៉ោង។

# សំណើ

***ប្រាក់ឈ្នួលអប្បបរមាកាន់តែខ្ពស់នៅឆ្នាំ 2025។*** នៅឆ្នាំ 2025 រដ្ឋ California នឹងមានប្រាក់ឈ្នួលអប្បបរមាខុសៗគ្នាសម្រាប់និយោជកដែលមានទំហំខុសៗគ្នា។ និយោជកដែលមាននិយោជិតចាប់ពី 26 នាក់ឡើងទៅនឹងមានប្រាក់ឈ្នួលអប្បបរមា $18 ដុល្លារក្នុងមួយម៉ោង។ និយោជកដែលមាននិយោជិត 25 នាក់ ឬតិចជាងនេះ នឹងមានប្រាក់ឈ្នួលអប្បបរមា $17 ដុល្លារក្នុងមួយម៉ោង។ បើគ្មានសំណើ 32 ប្រាក់ឈ្នួលអប្បបរមាសម្រាប់និយោជិតទាំងអស់នឹងមានប្រហែល $16.50 ក្នុងមួយម៉ោង។ សំណើនេះនឹងមិនផ្លាស់ប្តូរប្រាក់ឈ្នួលអប្បបរមាក្នុងតំបន់ ឬឧស្សាហកម្មជាក់លាក់ណាមួយឡើយ។

***ប្រាក់ឈ្នួលអប្បបរមា $18 ដុល្លារក្នុងមួយម៉ោងក្នុងឆ្នាំ 2026។*** នៅឆ្នាំ 2026 ប្រាក់ឈ្នួលអប្បបរមានឹងមានចំនួន $18 ដុល្លារក្នុងមួយម៉ោងសម្រាប់បុគ្គលិកទាំងអស់។ បើគ្មានសំណើ 32 វាទំនងជាប្រហែល $17 ដុល្លារក្នុងមួយម៉ោង។

***ការកែតម្រូវអតិផរណា ត្រូវបានផ្អាករហូតដល់ឆ្នាំ 2027។*** ប្រាក់ឈ្នួលអប្បបរមានឹងត្រូវបានកែសម្រួលសម្រាប់អតិផរណាជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ 2027។ ការកែតម្រូវទាំងនេះនឹងអនុវត្តតាមច្បាប់បច្ចុប្បន្នដែលបានពិពណ៌នាពីមុន។

## ផលប៉ះពាល់សារពើពន្ធ

***ឥទ្ធិពលសារពើពន្ធអាស្រ័យលើឥទ្ធិពលសេដ្ឋកិច្ច។*** សំណើ 32 អាចមានឥទ្ធិពលសេដ្ឋកិច្ចយ៉ាងទូលំទូលាយ៖

- ***ប្រាក់ឈ្នួលកាន់តែខ្ពស់។*** កម្មករដែលរកប្រាក់បានតិចជាង $18 ដុល្លារក្នុងមួយម៉ោង នឹងជំនួសវិញឱ្យរកប្រាក់បាន $18 ដុល្លារ ឬច្រើនជាងនេះក្នុងមួយម៉ោងនៅឆ្នាំ 2026។ ប្រាក់ឈ្នួលអប្បបរមាខ្ពស់ក៏មានទំនោរជំរុញប្រាក់ឈ្នួលដល់កម្មករផ្សេងទៀតដែរ។ នេះមានន័យថា និយោជិតជាច្រើនដែលកំពុងរកប្រាក់បានច្រើនជាង $18 ដុល្លារក្នុងមួយម៉ោងក៏ទំនងជានឹងទទួលបានការដំឡើងប្រាក់ឈ្នួលដែរ។
- ***ទំនងជាតម្លៃកាន់តែខ្ពស់។*** ប្រាក់ឈ្នួលកាន់តែខ្ពស់នឹងបង្កើនការចំណាយសម្រាប់អាជីវកម្មជាច្រើន។ អាជីវកម្មមួយចំនួនទំនងជានឹងគិតថ្លៃអតិថិជនកាន់តែខ្ពស់។ ការកើនឡើងតម្លៃជារួមពីសំណើ 32 ទំនងជានឹងតូចជាងពាក់កណ្តាលនៃ 1 ភាគរយ។
- ***ទំនងជាបន្ទាបប្រាក់ចំណេញ។*** ការចំណាយលើប្រាក់ឈ្នួលកាន់តែខ្ពស់ ទំនងជានឹងកាត់បន្ថយប្រាក់ចំណេញរបស់អាជីវកម្មមួយចំនួន។
- ***ឥទ្ធិពលលើការងារ។*** ចំនួនការងារនៅក្នុងរដ្ឋអាចឡើងឬចុះ។ ការផ្លាស់ប្តូរនេះទំនងជាតូចជាងមួយភាគបួននៃ 1 ភាគរយ។

***ការចំណាយរបស់រដ្ឋាភិបាលអាចឡើង ឬចុះ។*** សំណើ 32 នឹងបង្កើនការចំណាយរដ្ឋាភិបាលរដ្ឋ និងក្នុងតំបន់ តាមមធ្យោបាយមួយចំនួន ប៉ុន្តែនឹងកាត់បន្ថយតាមវិធីផ្សេងទៀត៖

- ***ការចំណាយកាន់តែខ្ពស់របស់រដ្ឋាភិបាលក្នុងការបង់ប្រាក់សម្រាប់បុគ្គលិក។*** រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់ជាច្រើន នឹងមានការចំណាយកាន់តែខ្ពស់ក្នុងការផ្តល់ប្រាក់ឈ្នួលឱ្យបុគ្គលិករបស់ខ្លួន។ ពួកគេក៏នឹងមានការចំណាយកាន់តែខ្ពស់ក្នុងការផ្តល់ប្រាក់ឈ្នួលលើការងារដែលធ្វើដោយបុគ្គលិកដែលមិនមែនជាបុគ្គលិករបស់ខ្លួន។
- ***ការសន្សំពីការចុះឈ្មោះកាន់តែទាបនៅក្នុងកម្មវិធីសុខភាព និងសេវាមនុស្ស។*** សំណើ 32 នឹងផ្លាស់ប្តូរចំនួនមនុស្សដែលបានចុះឈ្មោះក្នុងកម្មវិធីសុខភាព និងសេវាកម្មមនុស្ស (ដូចជាកម្មវិធី Medicaid California, Medi-Cal) ព្រោះវានឹងផ្លាស់ប្តូរប្រាក់ចំណូលរបស់មនុស្ស។ ការផ្លាស់ប្តូរការចុះឈ្មោះទាំងនេះ ទំនងជានឹងកាត់បន្ថយការចំណាយរបស់រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់។

**ការរួមបញ្ចូលគ្នារវាងខ្ទង់ចំណាយទាំងពីរនេះ ការចំណាយសរុបរបស់រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់អាចឡើង ឬចុះ។ ការផ្លាស់ប្តូរនេះ ទំនងជានឹងមិនលើសពីទឹកប្រាក់ខ្ពស់រាប់រយលានដុល្លារក្នុងមួយឆ្នាំ (ប្រចាំឆ្នាំ) ទេ។** (ការចំណាយសរុបរបស់រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់ក្នុងរដ្ឋ California លើសពី $500 ពាន់លានដុល្លារក្នុងមួយឆ្នាំ។)

ការផ្លាស់ប្តូរការចំណាយលើមូលនិធិទូទៅរបស់រដ្ឋទំនងជានឹងមានតិចជាងពាក់កណ្តាលនៃ 1 ភាគរយនៃថវិកាមូលនិធិទូទៅសរុបរបស់រដ្ឋ។ (មូលនិធិទូទៅគឺជាគណនីដែលរដ្ឋប្រើដើម្បីបង់ថ្លៃសេវាសាធារណៈភាគច្រើន រួមទាំងការអប់រំ ការថែទាំសុខភាព និងពន្ធនាគារ។)

***បន្ទាបចំណូល។*** សំណើ 32 នឹងប៉ះពាល់ដល់ពន្ធលើប្រាក់ចំណូល និងចំណូលពន្ធលើការលក់ ព្រោះវានឹងផ្លាស់ប្តូរចំណូល និងតម្លៃ។ ជារួម សំណើនេះទំនងជានឹងកាត់បន្ថយចំណូលរដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់។ ប្រាក់ចំណូលនឹងថយចុះជាចម្បងដោយសារតែប្រាក់ចំណូលកាន់តែទាបសម្រាប់ម្ចាស់អាជីវកម្ម។ ការបាត់បង់ប្រាក់ចំណូលសុទ្ធទំនងជាមិនលើសពីពីរបីរយលានដុល្លារក្នុងមួយឆ្នាំទេ។ កាលពីឆ្នាំមុន ចំណូលរដ្ឋ និងក្នុងតំបន់សរុបពីពន្ធទាំងនេះមានប្រហែល $200 ពាន់លានដុល្លារ។

**សូមចូលទៅកាន់ *sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2024-ballot-measure-contribution-totals* សម្រាប់បញ្ជីគណៈកម្មាធិការ បង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬប្រឆាំងវិធានការនេះ។**

**សូមចូលទៅកាន់ *fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលមើលកាន់អ្នកជួយវិភាគទានកំពូលទាំង 10 របស់គណៈកម្មាធិការ។**



សម្រាប់អត្ថបទពេញលេញស្តីពីសំណើ 32 សូមមើលទំព័រទី 97។